**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០៧០ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការបន្ថែមសមាជិកនៅក្នុងក្រុមប្រតិបត្តិសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការសំរាប់គោល នយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញឯកសារចក្ខុវិស័យនិងផែនការសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុពីឆ្នាំ២០០១-២០១០ ដែលត្រូវបានអនុម័តដោយ រាជរដ្ឋាភិបាលកាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០១

-បានឃើញស្មារតីនៃកិច្ចចរចារវាងតំណាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០១

-បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០១

-បានឃើញប្រកាសលេខ៩២១ សហវ.វស ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រតិបត្តិសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

## សំរេច

**ប្រការ១:** បន្ថែមសមាជិក០២រូបទៅក្នុងក្រុមប្រតិបត្តិ (Task Force) ប្រចាំនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរាប់កម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (Financial Sector Development Program, ADB Loan No 1859-CAM (SF) ) ។ សមាសភាពបន្ថែមក្នុងក្រុមប្រតិបត្តិនេះមានដូចទៅ:

| | | |
|---|---|---|
| ១-លោកស្រី ស៊ុន ណាលី | ប្រធានការិយាល័យគ្រប់គ្រងបំណុល | សមាជិក |
| ២-លោកស្រី អ៊ុន ខៃ | អនុប្រធានការិយាល័យគ្រប់គ្រងបំណុល | សមាជិក |

**ប្រការ២:** អគ្គលេខាធិការ ខុទ្ទកាល័យ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុព្រមទាំងសាមីខ្លួនដូចប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ០៣ ឆ្នាំ២០០៤

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចំឡងជូន:**

-ធនាគារជាតិនៃកម្ពុជា